**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកំពង់ចាម**
**រដ្ឋបាលក្រុងកំពង់ចាម**

ថ្ងៃព្រហស្បតិ៍ ១២កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨
ក្រុងកំពង់ចាម ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៥

# របាយការណ៍

**កម្មវត្ថុ** ៖ របាយការណ៍លទ្ធផលចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំង ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងគេហទំព័រគម្រោង(STA) ។

**យោង** ៖ លិខិតលេខៈ១៥៤ ល.ស.គ.ជ.អ.ប ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៥ របស់ .គ.ជ.អ.ប ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមជូនរបាយការណ៍ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៥ ដល់ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៥ នាងខ្ញុំបានដឹកនាំក្រុមការងារ៥រូប គម្រោង(STA) ចូលរួមវគ្គបណ្តុះបណ្តាលឆ្លុះបញ្ចាំង ស្តីពីការប្រើប្រាស់ និងការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងព័ត៌មាន នៅខេត្តក្រចេះ ។ រំលឹកឡើងវិញនូវអ្វីដែលបានបណ្តុះបណ្តាលរួចមកហើយ បន្ថែមនូវចំណុចខ្វះខាត និងដោះស្រាយនូវបញ្ហាជួបប្រទះ ដើម្បីធានាបាននូវការប្រើប្រាស់ និងការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងព័ត៌មាន គេហទំព័រ ក៏ដូចជាការផលិតព័ត៌មានវីដេអូតាមទូរសព្ទបានប្រសើរជាងមុនរបស់រដ្ឋបាលក្រុងគោលដៅទាំង៣ ប្រកបដោយគុណភាព និងមានប្រសិទ្ធិភាពខ្ពស់ ។

"អក្ខរកម្មឌីជីថល" គឺជាជំនាញចាំបាច់ក្នុងការប្រើប្រាស់និងការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងព័ត៌មានក្នុងបង្កើតវេបសាយ(Website)ក្នុងការផ្សព្វផ្សាយព័ត៌មាន ដើម្បីយល់ដឹងក្នុងការទំនាក់ទំនង ការវាយតម្លៃ និងការបង្កើតព័ត៌មានវីដេអូតាមទូរសព្ទប្រកបដោយសុវត្ថិភាព និងត្រឹមត្រូវតាមរយៈឧបករណ៍ឌីជីថលព័ត៌មាន និងបច្ចេកវិទ្យាបណ្តាញ សម្រាប់ការចូលរួមនៅក្នុងជីវិតសេដ្ឋកិច្ច និងសង្គម។ជារួមបញ្ចូលទាំងសមត្ថភាពដែលរួមមាន អក្ខរកម្មកុំព្យូទ័រ អក្ខរកម្មបច្ចេកវិទ្យាទូគមនាគមន៍ និងព័ត៌មានវិទ្យា អក្ខរកម្មឌីជីថលព័ត៌មាន និងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ។ ជំនាញអក្ខរកម្មឌីជីថល បានរួមបញ្ចូលទាំងជំនាញរឹង (Hard skills) ដែលទាក់ទងទៅ នឹងការប្រើប្រាស់ឧបរណ៍ និងកម្មវិធីឌីជីថលព័ត៌មានដែលទាក់ទងទៅនឹងការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ និងឌីជីថលព័ត៌មាន ។ សូចនាករនេះត្រូវបានវាស់វែងតាមរយៈទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាល ដែលក្នុងនោះអ្នកចូលរួម វាយតម្លៃចំណេះដឹង និងជំនាញផ្ទាល់ខ្លួនរបស់ពួកគេទៅលើ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងឌីជីថល (MIDL) ។ មានពីរក្រុមនៃអ្នកចូលរួមដោយផ្អែកទៅលើវគ្គបណ្តុះបណ្តាលផ្សេងគ្នា ។ ក្រុមដំបូងនឹងអាចជាគ្រូបង្គោល ឬអ្នកសម្របសម្រួលនៃវគ្គបណ្តុះបណ្តាលនេះ ចំណែកក្រុមទីពីរជាប្រជាពលរដ្ឋទូទៅដែលអាចជាជនងាយរងគ្រោះ ។

**អ្នកធ្វើរបាយការណ៍**